- រដ្ឋលេខាធិការដ្ឋានកិច្ចការនារី ចំនួន : ១៦០.០០០.០០០៛
- រដ្ឋលេខាធិការដ្ឋានទំនាក់ទំនងជាមួយសភា : ២០.០០០.០០០៛

មាត្រា២: សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីនៃក្រសួងពាក់ព័ន្ធត្រូវទទួលអនុវត្តន៍អនុក្រឹត្យនេះចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខានេះតទៅ ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
| ព្រះហស្តលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| នរោត្តម រណឫទ្ធិ | ហ៊ុន សែន |

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៩៤

## អនុក្រឹត្យលេខ ៣៩ អនក្រ

### ស្តីពី

### ការលុបចោល អនុក្រឹត្យលេខ ១១ អ.ន.ក្រ ចុះថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើតគណៈកម្មការចំរុះ បង្ការបង្ក្រាប សកម្មភាព លួច ឆក់ ប្លន់ ប្រដាប់អាវុធ

### រាជរដ្ឋាភិបាល

-បានឃើញ រដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា

-បានឃើញ ព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេច ព្រះនរោត្តម សីហនុវរ្ម័ន ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា

-តាមសំណើរបស់ សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ

## សំរេច

**មាត្រា ១** : ត្រូវទុកជានិរាករណ៍ អនុក្រឹត្យ លេខ ១១ អ.ន.ក្រ ចុះថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ១៩៩៤ ស្តីពី ការបង្កើត គណៈកម្មការចំរុះបង្ការបង្ក្រាបសកម្មភាព លួច ឆក់ ប្លន់ ប្រដាប់ អាវុធ ។

**មាត្រា ២** : នគរបាលជាតិ កងយោធពលខេមរភូមិន្ទ និង កងរាជអាវុធហត្ថជាតិ ត្រូវទទួលបន្ទុកសហការ បង្ការបង្ក្រាបសកម្មភាព លួច ឆក់ ប្លន់ ប្រដាប់អាវុធ តាមភារកិច្ច និង សិទ្ធិ រៀងៗខ្លួន ដែលរាជរដ្ឋាភិបាល បានប្រគល់អោយ។

**មាត្រា ៣** : សហរដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារប្រទេស អគ្គសេនាធិការកងយោធពលខេមរភូមិន្ទ អភិបាលគ្រប់ ខេត្ត ក្រុង ត្រូវទទួលបន្ទុកអនុវត្តតាមអនុក្រឹត្យនេះ អោយមានប្រសិទ្ធិភាពខ្ពស់ ចាប់ពីថ្ងៃ ឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
|---|---|
| ព្រះហស្តលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| នរោត្តម រណឫទ្ធិ | ហ៊ុន សែន |

* * *